CITY OF LONG BEACH **PRESS RELEASE**

**សេចក្តីប្រកាសពត៌មាន**

ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ ២០២០

ទំនាក់ទំនង: មជ្ឈមណ្ឌលពត៌មានរួម សាលាក្រុងឡុងប៊ីឆ, 562.570.NEWS, jic@longbeach.gov

សំរាប់ផ្សព្វផ្សាយបន្ទាន់

# កម្មវិធីអាហារ 'បានបញ្ជូនអោយនូវចានដ៏អស្ចារ្យ ឬ Great Plates Delivered' សំរាប់ចែកជូនដល់មនុស្សចាស់ បានពន្យារពេល រហូតដល់ ថ្ងៃទី ៩ ខែសីហា

ក្រុងឡុងប៊ីឆ, រដ្ឋកាលីហ្វ័រញ៉ា — ទីក្រុងឡុងប៊ីឆបានពន្យារពេល កម្មវិធី Great Plates Delivered Program, ដែលជាសេវាកម្មបញ្ជូនអោយនូវអាហារឥតគិតថ្លៃ សម្រាប់មនុស្សចាស់ ដែលមានសិទ្ធិទទួលបាន ដែលមានផលប៉ះពាល់ ដោយសារ ជំងឺរាតត្បាត COVID-19, រហូតដល់ថ្ងៃទី ៩ ខែសីហា ឆ្នាំ ២០២០។ ព័ត៌មាននេះ កើតឡើង បន្ទាប់ពីទីភ្នាក់ងារគ្រប់គ្រងគ្រោះអាសន្នសហព័ន្ធ (FEMA), ដែលផ្តល់ ថវិការដល់កម្មវិធីនេះ, បានអនុញ្ញាតិអោយមានការពន្យារពេល សំរាប់បណ្តា ទីក្រុង និងខោនធីនានា នៃរដ្ឋកាលីហ្វ័រញ៉ា។

អភិបាលក្រុង Robert Garcia មានប្រសាសន៍ថា "យើងទន្ទឹងរង់ចាំ បន្តផ្តល់អាហារដោយឥតគិតថ្លៃដល់មនុស្សចាស់ ខណៈពេលកំពុងគាំទ្រភោជនីយដ្ឋាននានាក្នុងស្រុក"។ "យើងសូមថ្លែងអំណរគុណចំពោះដៃគូរដ្ឋ និង FEMA ក្នុងការផ្តល់ថវិការដល់ពួកយើងយើង ដើម្បីបន្តកម្មវិធីនេះ"។

CITY OF LONGBEACH

# PRESS RELEASE

Great Plates Delivered បានចាប់ផ្តើមនៅទីក្រុងឡុងប៊ីឆ នៅថ្ងៃទី ៩ ខែមិថុនា ហើយចាប់តាំងពីពេលនោះមក បានផ្តល់អាហារជាង ២៧,៣០០ ដល់មនុស្សចាស់ ច្រើនជាង ៣៩០ នាក់ ដែលមានការប៉ះពាល់ដោយសារវិបត្តិសុខភាព។ ផងដែរ កម្មវិធីនេះក៏បានបង្កើតនូវផលប៉ះពាល់សេដ្ឋកិច្ចក្នុងស្រុក ជាង ៩០០,០០០ ដុល្លារ ចាប់តាំងពីបានបង្កើតវាឡើងមក, ដោយមានការចូលរួមពីភោជនីយដ្ឋាន និង អ្នកផ្តល់អាហារនានា ដែលមានមូលដ្ឋាននៅទីក្រុងឡុងប៊ីឆ ចំនួន ១៦ ដែលកំពុង រៀបចំអាហារដែលបានចែកចាយ។ អ្នកផ្គត់ផ្គង់ស្បៀងអាហារក្នុងស្រុក បាន ប្រគល់ ជូននូវកិច្ចសន្យានានា ជាមួយនឹងទីក្រុង តាមរយៈដំណើរការដេញថ្លៃ ក្នុងខែឧសភា, និងរួមបញ្ចូលនូវតំណាង មកពីមួបជនជាតិផ្សេងៗគ្នា ដែលឆ្លុះបញ្ចាំងនូវវប្បធម៌របស់សហគមន៍ឡុងប៊ីឆ។

អភិបាលរដ្ឋ Gavin Newsom បានប្រកាសកម្មវិធីនេះ ជាលើកដំបូង នៅក្នុងខែមេសា ក្នុងនាមភាពជាដៃគូរ ជាមួយនឹងបណ្តាខោនធី, ទីក្រុង និងកុលសម្ព័ន្ធនានា ក្នុងកិច្ចខិតខំប្រឹងប្រែងមួយ ដើម្បីរក្សាប្រជាជនវ័យចំណាស់ អោយមានសុខភាពល្អ និងនៅផ្ទះ ខណៈពេលដែល មានការផ្តល់នូវការជំរុញសេដ្ឋកិច្ចដល់ អាជីវកម្ម ដែលចាំបាច់ក្នុងស្រុកនានា ដែលកំពុងតស៊ូ ដើម្បីអោយនៅអណ្តែត ឬដំណើរការបាន ក្នុងពេលមានវិបត្តិជំងឺ COVID-19។

ការធ្វើអោយមនុស្សចាស់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ អាចនៅចូលរួមក្នុងកម្មវិធីនេះបាន ដោយការដាក់នូវពាក្យស្នើសុំតាមអ៊ីនធឺណិត ដោយទស្សនាគេហទំព័រ longbeach.gov/seniormealdelivery, ទូរស័ព្ទទៅលេខ (562) 570-INFO (4636) ហើយជ្រើសរើសជម្រើសលេខ ៥ ឬអ៊ីម៉ែលទៅកាន់ GreatPlatesLB@longbeach.gov.

សម្រាប់ព័ត៌មានថ្មីៗចុងក្រោយ ស្តីពីជំងឺ COVID-19, ដែលលំអិតអំពីអ្វីៗទាំងអស់ ដែលទីក្រុងឡុងប៊ីឆកំពុងធ្វើ ដើម្បីការពារសុវត្ថិភាពដល់ប្រជាជនរបស់យើង, ទស្សនា: longbeach.gov/COVID19 និងតាមមើល @LongBeachCity នៅលើ Facebook, Twitter និង Instagram.

###